ស្បើយចិត្តណាស់ដែរ ពេលមានអ្នកសរសេរទាំងនេះធ្វើឲ្យវរសេនីយ៍ត្រីរកនឹកឃើញសំណួរសួរលេង តបវិញ៖

«ចុះឥឡូវខ្ញុំសួរពូវិញ! សាកបិទភ្នែកស្រមៃថា ពេលនេះពូកំពុងនៅលើទូកមួយតែឯងកណ្តាលសមុទ្រហើយចោមព័ទ្ធទៅដោយហ្វូងឆ្លាមកំណាច! ពេលនេះពូកំពុងភ័យខ្លាចយ៉ាងខ្លាំងតើពូធ្វើម៉េចអាចចាកចេញពីគ្រោះថ្នាក់នោះ?»

គេញញឹមពេលឃើញពូតែកុងបិទភ្នែកស្រមៃហើយធ្វើមុខពិបាកឡើងៗ។

គេទ្រាំមិនបានក៏សើចខឹកៗធ្វើឲ្យគាត់បើកភ្នែកមកវិញហើយរអ៊ូបន្ទោសខ្លួនឯង៖

«ពូល្ងង់ណាស់ នឹកមិនឃើញទេ!»

«ចង់ដឹងចម្លើយ?»

គាត់ងក់ក្បាល ចិត្រាសើចវែងអន្លាយហួសចិត្តមុនពេលឆ្លើយប្រាប់៖

«ចម្លើយស្រួលដូចបកចេញគឺ គ្រាន់តែឈប់ស្រមៃទៅ!»

គាត់នៅតែមិនយល់ នៅទ្រឹងរកនឹកបន្តិចមុនពេលភ្ញាក់ដឹកខ្លួនហើយសើចក្អាកក្អាយ។

ចិត្រារង់ចាំដល់គាត់សើចចប់។ គេចាប់ផ្តើមពន្យល់៖

«ប្រស្នាកាន់តែល្អិត រឹតតែសម្បូរចំណុចខ្សោយ!»

បុរសចំណាស់ប្រញាប់សួរចាក់ដោយជក់ចិត្ត៖

«ប្រាប់គន្លឹះដល់ពូផង?»

«មានអីពិបាកទេ! នៅរាល់ពេលដែលពូស្តាប់ប្រស្នាបែបនេះ ត្រូវចាំថា អ្នកសួរតែងបង្កប់ចំណុចបំភ័ន្តមួយនៅខាងដើមសំណួរ! ឧទាហរណ៍ដូចជា  បុរសម្នាក់ស្លៀកពាក់ខ្មៅក្រឹបកំពុងដើរម្នាក់ឯងតាមផ្លូវដែលគ្មានពន្លឺភ្លើង ពូចាប់អារម្មណ៍តែពណ៌ខ្មៅ និងគ្មានពន្លឺ ម្តេចមិនចាប់អារម្មណ៍ផងថាថ្ងៃ ឬក៏យប់? ចំណែកសំណួរខ្ញុំមិញនេះ បិទភ្នែកស្រមៃថា ពេលនេះពូកំពុងនៅកណ្តាលទន្លេ ចំណុចត្រូវស្រាយគឺនៅនឹងពាក្យស្រមៃ ចុះបើមិនស្រមៃ បានអីនឹងមានគ្រោះថ្នាក់?»

គេថាចប់ក៏ញញឹមសម្លឹងគាត់ តែគាត់វិញ ញញឹមដូចគ្នា គ្រាន់តែមិនទាន់លះ។ គាត់និយាយទាំងមិនអស់ចិត្តៈ

«ពូប្រាជ្ញាអន់ណាស់ ដល់ក្មួយមកពន្យល់យល់ដែរ តែយល់មិនទាន់លះសោះ!»

ពូហឿនក្រពាត់ដៃហាក់ជក់ចិត្តនិងការដោះប្រស្នានេះជាខ្លាំង រហូតដល់ចិត្រាមិនអាចបញ្ឈប់ត្រឹមនេះ។ វរសេនីយ៍ត្រីក៏ងក់ក្បាលនិយាយតបៈ

«តោះ! តទៀតអ៊ីចឹង! សំណួរថ្មី ចុះបើមួយឆ្នាំៗ ខែខ្លះមាន៣១ ថ្ងៃ ហើយខែខ្លះទៀតមាន 30 ថ្ងៃតើមានខែប៉ុន្មានមាន 28 ថ្ងៃ? »

គាត់អេះក្បាល។ ចិត្តមួយចង់ឆ្លើយថាកុម្ភៈ តែបើឆ្លើយថាកុម្ភៈ ចុះបើកុម្ភៈខ្លះមានម្ភៃប្រាំបួនថ្ងៃគិតយ៉ាងណា?

ដល់វេនចិត្រាឆ្លើយប្រាប់តែម្តងៈ

«ចម្លើយគឺ ខែណាក៏មាន២៨ថ្ងៃដែរពូ!»

គាត់វាយថ្ងាសផ្ទូង  ទុកឲ្យចិត្រាក្រពាត់ដៃសើច។

បុរសចំណាស់នេះជក់នឹងប្រស្នាពេកហើយ គាត់ប្រាកដជាធ្លាប់នឹកចង់ធ្វើប៉ូលិសស៊ើបក្តីពិតណាស់។ អ៊ីចឹងហើយ បានជាចូលមកធ្វើការនៅផ្ទះនៅផ្ទះប៉ូលិសបាន?

«ពូចង់ក្លាយជាអ្នកស៊ើបមែនអត់?»

គាត់ងក់ក្បាលទទួលភ្លាមហើយឆ្លើយតបវិញអៀនអន់ៈ

«តែពូប្រលងចូលសាលាហ្វឹកហ្វឺនមិនជាប់! ហឹម...ពូក្មួយគេសុទ្ធតែពូកែៗ! ពូកោតហើយ!»

សាជាថ្មី ពេលនឹកដល់ពូរបស់ខ្លួន វរសេនីយ៍ត្រីស្រពោនវិញ តែគេបន្លប់ហើយនិយាយបន្ថែមទៅកាន់ពូហឿនៈ

«ខ្ញុំឯណាពូកែដូចគាត់! និយាយទៅស្ថានភាពក៏មិនខុសពីពូប៉ុន្មានដែរ! ចង់ធ្វើអ្វីមិនបានធ្វើ! ដឹងជាតិនេះបានស៊ើបក្តីនឹងគេដែរអត់?»

ពូហឿនចាប់ផ្តើមនិយាយលួងៈ

«អស់សង្ឃឹមធ្វើអី! គ្មានប៉ូលិសណាចាប់ផ្ដើមភ្លាម បានកាន់សំណុំរឿងភ្លាមទេ!»

វរសេនីយ៍ត្រីនៅស្ងៀមស្ងាត់ ព្រោះដឹងថាបុរសចំណាស់នេះកំពុងតែលើកទឹកចិត្តខ្លួន ប៉ុន្តែសេចក្ដីសង្ឃឹមដែលថាអាចដោះស្រាយសំណុំរឿងនៅឆ្ងាយនៅឡើយ បើមើលលើស្ថានការណ៍ពេលនេះ។

រំពេចនោះ នាយនឹកឃើញដល់ស្នងការ Roy ដែលមើលពីក្រៅទៅហ៊ឹកហ៊ាក់ ធាតុពិតខាងក្នុងមករករឿងឈ្លោះសូម្បីតែជាមួយនឹងមនុស្សដែលមានឋានៈទាបជាង។ តើនាយ Roy មានទំនាស់អ្វី ឬធ្លាប់ថាចាញ់ចិត្តអ្វីមួយជាមួយលោកមាដែរអត់?

បើបុរសចំណាស់នេះធ្លាប់ដឹងរឿងចាស់ៗជាន់មុន គេទំនងជាដឹងរឿងខុសទាស់រវាងពូខ្លួននិងនាយ Roy នោះផងក៏ថាបាន។ មិនទាន់បានហើបមាត់សួរផង បុរសនោះទះស្មាវរសេនីយ៍ត្រីផាំងដោយមិនមានក្រែងចិត្ត។

«ក្មួយប៉ូលិសដែលឮសំណុំរឿងឃាតកម្មស្ទូឪយោលេខ៧ទេ?»

ចិត្រាញញឹមមិនទាន់ បន្លាយមិនឆ្លើយទុកឲ្យបុរសតែកុងឆ្លើយចាក់បណ្ដោយះ

«រឿងអីថាមិនដែលឮ បើពូខ្លួនឯងល្បីនឹងរឿងនេះ?»

«បាទ!»

គេចាក់បណ្ដោយវិញ។

«តែក្មួយប៉ូលិសដឹងដែរអត់ ថាកាលឧត្តមសេនីយ៍រិទ្ធដោះស្រាយរឿង ស្ទូឪយោលេខ៧ គាត់ជួយមិត្តភ័ក្តិ ម្នាក់ដែលស្គាល់នាយកស្ថានីយ! ពីដំបូង គាត់មិនបានទទួលបញ្ជាពីថ្នាក់លើឲ្យកាន់សំណុំរឿងនេះឯណា?»

អ្វីម្យ៉ាងភ្លោចឡើងក្នុងបេះដូងប៉ូលិសក្មេង។

សំណួរលេចឡើងមកភ្លាមថា ហេតុអ្វីបានជាខ្លួនមិនដែលដឹងរឿងនេះ?

មិនបានទទួលបញ្ជារបស់ថ្នាក់លើ ហេតុអីបានជា គាត់អាចមានមធ្យោបាយបំបែកករណីឃាតកម្មនោះបាន?

«ម្ចាស់ស្ទូឌីយោលេខ៧ ជាមិត្តភក្តិរបស់ប៉ូលិសព្រហ្មទណ្ឌម្នាក់ទៀត ដែលកាន់នៅតំបន់នោះ! ហើយប៉ូលិសនោះជាមិត្តរបស់ឧត្តមសេនីយ៍រិទ្ធ! ក្តីមួយនោះប៉ះចំជាឃាតករសញ្ជាតិអាមេរិក! ល្បីសម្បើមណាស់ ព្រោះបុគ្គលិកស្រីៗ ពីរនាក់ស្លាប់បន្តគ្នា! ចុងក្រោយ ពូក្អួយបានឡើងឋានៈផ្លាស់មកភ្នំពេញ!»

បុរសតៃកុងនេះ មានការចងចាំល្អណាស់ មិនសមថាគ្រាន់តែជាអ្នកបើកឡានម្នាក់នោះឡើយ។

ទោះយ៉ាងណា ចិត្រានៅស្ងៀមចំហមាត់ ចិត្តប្រឹងរំលឹកឡើងវិញ អំពីបណ្តាឯកសារទាំងឡាយដែលខ្លួនធ្លាប់បានអានទាក់ទងទៅនឹងសំណុំរឿងឃាតកម្មនៅវិទ្យុមួយនោះ។

ភាគទី៤

សំឡេងគាត់នៅតែបន្តមកបន្ថែមហាក់ដូចព្យាយាមដាក់ប្រស្នានាយគិតវិញម្តង៖

«ចុះរឿង FolderZ22?»

ចិត្រាងាកសម្លឹងមុខគាត់ នាយប្រិចភ្នែកគិតមុនពេលនិយាយ៖

«ខ្ញុំដឹងថា មីងភីណាបានពឹងគាត់ឲ្យជួយដោះបន្ទុកមេធាវីអាមេរិកម្នាក់ ដែលជាន់ដានគេ! ពូខ្ញុំមិនមានភារកិច្ចអីកាន់សំណុំរឿងឃាតកម្មហ្នឹងទេ!»

«តែគាត់បានលូកដៃជ្រៅរហូតដល់សឹងស្លាប់ខ្លួនជាមួយឪពុកកូនដែលជាអ្នកលេងគីមីយ៉ាងសាហាវនោះទៀត!»

ស្នូររថយន្តលាន់មកស្រាលស្ទើកនៅរបងក្រៅ។

ពូហឿនកាត់ផ្តាច់ការជជែកវែកញែក ហើយរួសរាន់ប្រាប់នាយប៉ូលិសយើង៖

«ភ្ញៀវលោកជំទាវអញ្ជើញមកហើយ! »

ឃើញគាត់តក់ក្រហល់ ចិត្រាធ្វើភ្នែកស្លឹ ដូច្នេះបុរសចំណាស់ពន្យល់វិញ៖

«គេមកមើលអ្នកនាងអមរា! គ្រួសារខាងកូនកំលោះ!»

ចិត្រាកាន់តែភ័ន្តភាំង។

អូ! ថ្ងៃយើងចូលបម្រើការដំបូង ចំថ្ងៃគេមកស្ដីដណ្ដឹងអ្នកនាងតូចម្ចាស់យើង?

បុរសចំណាស់និយាយបន្ថែមមុនរត់ទៅបើកទ្វារៈ

«ឧត្ដមសេនីយ៍ជាប់ធុរៈមិននៅផ្ទះចំថ្ងៃដែលខាងប្រុសគេណាត់យូរហើយ! លោកជំទាវកំពុងខំរកវិធីសម្រួលបរិយាកាស!»

ចិត្តមួយវរសេនីយ៍ត្រីនឹកស្ងើចសរសើរលោកឧត្ដមសេនីយ៍ ដែលតម្កល់ទុកការងារជាអាទិភាព ចិត្តមួយនឹកចង់ឃើញសាមីខាងប្រុសណាទៅដែលប្រាថ្នាចូលមកជាអនាគតកូនប្រសាគាត់។

«ខ្ញុំដឹងថា ឯងមិនមែនជាប៉ូលិសធម្មតាទេ! ខ្ញុំផ្ញើជីវិតកូនស្រីតែមួយគត់របស់ខ្ញុំ ក្នុងដៃឯង ឯងគួរយល់ហើយ!»

សម្ដីនិងទឹកមុខស្រងូតរបស់គាត់នៅស្នងការដ្ឋានហាក់ចង់បញ្ជាក់ប្រាប់នាយថា សូម្បីបុរសជាអនាគតកូនប្រសានេះ ក៏គាត់មិនអាចពឹងពផ្ញើបុត្រីបាន?

«សួស្ដីពូ!»

សំឡេងដូចធ្លាប់ស្គាល់?

វរសេនីយ៍ត្រីងើបមុខសម្លឹងអ្នកដែលទើបមកដល់ ហើយចុះមកពីលើឡាន។

បុរសនោះធ្វើឲ្យនាយប៉ូលិសភ័ន្តភាំង ចំពោះទឹកមុខដ៏មានអំនួតរបស់នាយ ហើយក៏គ្មានអ្នកណាក្រៅពីស្នងការមកពីក្រុងឡុងដ៍ដែលទើបនឹងធ្វើឲ្យនាយឆ្អែតបាយកាលពីព្រហាមមិញនេះ។

«ហេតុអីជាអាគាត់ Roy ទៅវិញ? គេនេះហ្អីអនាគតជាកូនប្រសាលោកឧត្ដមសេនីយ៍ ឱិតសាម៉ុន?»

នាយ Roy ដើរកាត់ពីមុខប៉ូលិសអង្គរក្សជាមួយទឹកមុខសោះអង្គើយ ធ្វើដូចជាមិនដែលស្គាល់គ្នា។ គេមានទាំងម្ដាយនិងឪពុក មីងមាបីបួនឡាន មកជាមួយនិងគ្រឿងបណ្ណាការគ្រប់ដៃ។

ក្នុងកែវភ្នែកពួកគេ វរសេនីយ៍ត្រីត្រឹមតែជាអ្នកបម្រើម្នាក់នៃគ្រួសារខាងស្រី ដូច្នេះហើយស្នាមញញឹមមួយក៏ពួកគេមិនប្រគល់មកឲ្យដែរ។

ចិត្តបុរសក្មេងនេះ ស្រាប់តែចេះស្រពោនហើយនឹកភ្នកក្នុងចិត្តម្នាក់ឯងស្ងាត់ៗ មិនឲ្យមានគេដឹង៖

«អ្នកនាងអមរាជា កូនស្រីទោលដែលលោកឧត្តមសេនីយ៍ស្រលាញ់ស្មើជីវិត ហេតុអីត្រូវជាគូនឹងមនុស្សលាក់ពុតធុននេះ? ឬមួយយកគេទុកដាក់កូនចៅមើលតែលើឋានៈសង្គមប៉ុណ្ណោះ?»

ពួកគេចូលផុតទៅក្នុងផ្ទះធំ ហើយពូហឿនក៏ជាប់រវល់ រត់ទៅជួយរៀបចំនេះនុះទទួលភ្ញៀវលំដាប់។

ចិត្រាយល់ហើយថា ហេតុអ្វីបានជា មីងម៉ាឡាត្រូវបានលោកជំទាវហៅប្រើបន្ទាន់ម្ល៉េះកាលដែលខ្លួនទើបនឹងមកដល់ពីព្រឹក។

ចិត្តនាយពេលនេះចង់ដឹងបំផុតថា ចំណងខាន់ស្លានេះនឹងវិវត្តទៅរបៀបណា ហើយរឹតតែចង់ដឹងណាស់ទៅទៀត អំពីមនោសញ្ចេតនាពិតប្រាកដរវាងអ្នកនាងតូចនិងបុរសលាក់ពុត។

«ប៉ាកូនដាទៅស្នងការតាំងពីម៉ោងបីភ្លឺ! គាត់ពិបាកចិត្តរឿងបាត់មនុស្ស!»

សំឡេងលោកជំទាវវ៉ាស៊ីកាន់តែទាញអារម្មណ៍វរសេនីយ៍ត្រីឲ្យចង់ឃើញសភាពការណ៍ខាងក្នុង ម្ល៉ោះហើយនាយចាប់ផ្តើមឈានទៅក្រោយបង្អួចធំមួយក្បែរគុម្ពផ្កាហើយរកវិធីបង្ខើបកញ្ចក់ញែកវាំងននសម្លឹងទៅខាងក្នុង។

នាយ Roy មានអាការៈជាសុភាពបុរសពិតៗអង្គុយបត់ជើងកណ្តាលចំណោមចាស់ទុំ។

ខាងស្រីមិនមែនមានតែលោកជំទាវដូចនាយស្មានឯណា មនុស្សម្នាជាច្រើនមិនក្រោម១០នាក់ កំពុងអង្គុយតំណាងឲ្យភាគីម្ចាស់ផ្ទះតទល់នឹងខាងប្រុសវិញដែរ។

មីងម៉ាឡានិងអ្នកបម្រើស្រីកំពុងសស្រាក់សស្រាំ ក្នុងការរៀបចំចំណីអាហារទទួលភ្ញៀវ។

«កូនដាកំពុងឆុងតែ!»

លោកជំទាវមានប្រសាសន៍ប្រាប់ចាស់ទុំរឹងរឹតតែដុតចិត្ត វរសេនីយ៍ត្រីដែលនៅក្រៅសង្វៀនឯណោះឲ្យកើតចិត្តចង់ឃើញធីតាយើងទ្វេឡើង។

«ល្អហើយ ជាកូនស្រីអ្នកខ្ពង់ខ្ពស់ ថ្លៃថ្នូរហើយចេះចូលផ្ទះបាយខ្លួនឯងទៀត!»

ម្ដាយខាងប្រុសពោលសរសើរធ្វើឲ្យនាយ Roy អង្គុយញញឹមបិទមាត់មិនជិតឡើយ។ ឃើញសភាពនេះកាលណា ចិត្តនរៈដែលលបលួចមើលនៅខាងក្រៅចាប់ផ្ដើមនឹកក្ដៅក្រហាយមិនសុខសោះ។

កិរិយាបុរសស្មុងការមិនស្មោះសរ ចេះតែធ្វើឲ្យចិត្រាលបគិតទោមនស្សថា គេម៉េចនឹងសមបានចូលមកក្នុងគ្រួសារដ៏ថ្លៃថ្នូរហើយមានកូនស្រីតែមួយនេះទៅ?

នាយរំពៃរកមើលលើជញ្ជាំងក្រែងឃើញរូបសម្រស់អ្នកនាងតូចតាំងនៅ ប៉ុន្តែរូបទាំងនោះនៅឆ្ងាយហើយមិនធំពេកដែលអាចឲ្យឃើញច្បាស់ទម្រង់មុខមាត់តាមចិត្តអន្ទះសាឡើយ។

«សូមជម្រាបសួរ!»

គេងាកមកវិញបន្ទាន់ ពេលឮសំឡេងស្រទន់របស់នាង។

នេះជាសំឡេងរបស់មនុស្សស្រីដែលស្អាតទាំងកាយចិត្តពិតណាស់។

នាយសម្លឹងចំហមាត់ទៅកាន់កុលធីតារបស់លោកឧត្ដមសេនីយ៍ ឱិត សាម៉ុន ដែលនាំមុខអ្នកបម្រើស្រីៗក្មេងៗពីរបីនាក់ លើកថាសដែលមានពែងតែជាច្រើនចេញមក។

សម្រស់នាងពិតជាអាចធ្វើឲ្យគេហដ្ឋានទាំងមូលទៅជាស្ងាត់ជ្រងំបាន ព្រោះថាគ្រប់គ្នាសឹងតែភ្លេចដកដង្ហើម។

«តើស្រីស្អាតម្នាក់នេះមែនទេ ដែលនឹងមកជាម្ចាស់របស់យើង! ហើយចុងក្រោយនាងនឹងក្លាយជាភរិយារបស់អាគាត់ Roy?»

អ្នកណាម្នាក់កេះស្មានាយ ធ្វើឲ្យនាយបែរមកវិញទាំងព្រលឹងចុងសក់។

គឺពូហឿន គាត់ញញឹមហើយហុចទូរសព្ទមកឲ្យ៖

«លោកឧត្ដមសេនីយ៍រកក្មួយប៉ូលិស!»

ចិត្រាអៀនខ្មាសបុរសនេះណាស់ ដែលត្រូវគាត់មកទាន់ពេលកំពុងលបមើលកូនគេភ្លឹកស្មារតី។ ចំណែកពូហឿនក៏មិនបានបញ្ចេញចេញកាយវិការអ្វីវាយតម្លៃនាយ ដោយគិតពីងាកទៅជូតឡានបំពេញការងាររបស់គាត់វិញដូចប្រក្រតី។

«ជម្រាបប្រសាសន៍ទាន!»

នាយហៅតិចៗ តបនឹងខ្សែទូរសព្ទដែលមានមនុស្សកំពុងរង់ចាំ។ សំឡេងក្រអួនមានអំណាចរបស់ ឧត្តមសេនីយ៍ ឱត សាម៉ុនតបមកវិញ៖

«ចិត្រា! រឿងអលង្ការសត្វនាគហាមផ្សព្វផ្សាយ!»

សម្ដីគាត់ខ្លី តែវាជាបទបញ្ជា។ បើទោះបីជាចិត្តងឿងឆ្ងល់ នាយនៅតែចាំបាច់ត្រូវឆ្លើយតប៖

«ទទួលបញ្ជាទាន!»

គាត់ដាក់ទូរសព្ទចុះបង្ហាញថា បុរសនេះពិតជាកំពុងជាប់រវល់វិលក្បុង កុំថាឡើយមកមើលកូនស្រីត្រូវគេចូលដណ្ដឹង សូម្បីតែនិយាយទូរសព្ទឲ្យបានចប់ចុងចប់ដើមក៏មិនមានពេលផង។

នាយហុចទូរសព្ទសងពូហឿន ហើយសម្លឹងគាត់ភ្លឹះៗមុនពេលដាច់ចិត្តសួរ៖

«ពូ អ្នកនាងពូកើតឆ្នាំរោង?»

ពូហឿនងក់ក្បាលដោយមិនបាច់គិតយូរ បញ្ជាក់ថាបុរសនេះ ពុំមែនចូលមកនៅផ្ទះនេះឥឡូវៗនោះឡើយ។ ចិត្រាដកដង្ហើមធំ ភ្នែករេសម្លឹងបណ្ដារថយន្តទំនើបដែលចតជាជួរ។

គ្រួសារខាងប្រុសប្រាកដជាអាងទ្រព្យធនជាធំហើយ បានជាចង់បានកូនស្រីផ្ទះនេះ ហើយមើលទៅគ្មានអ្វីជាឧបសគ្គសម្រាប់ពួកគេនោះទេ បើពឹងលើឋានៈសង្គមនិងមុខងារដែលត្រូវគ្នាឥតទាស់។

«នៅក្នុងផ្ទះមានរឿងសិរីសួស្ដី ស្ដាយឧត្តមសេនីយ៍មិនបាននៅផ្ទះ!»

«មកពីគាត់មិនពេញចិត្ត!»

សំឡេងពូហឿនឆ្លើយមកខ្សឹបៗស្រាលៗមែន តែចិត្រាស្ដាប់ឮច្បាស់ហើយភ្ញាក់ខ្លួនព្រើត។ សំណួរមួយលេចឡើងក្នុងចិត្តនាយ «មិនដែលឪពុកឯណាសុខចិត្តចោលថ្ងៃសួស្ដីរបស់កូន វាមានតែគាត់ពិតជាមិនទាន់ពេញចិត្តកូនកំលោះ ដូចសម្ដីរបស់តែកុងម្នាក់នេះមែន!»

នាយងាកសម្លឹងមុខគាត់ភ្លឹះៗ បុរសចំណាស់ក៏ញាក់ចិញ្ចើមតបហើយនិយាយខ្សឹបៗ៖

«ភ្នាល់ទៅបើស្នងការ Roy ដណ្តឹងបានអ្នកនាងអមរាដា!»

ចិត្រាលែងមាត់ គេថយទៅទីតាំងចាស់ហើយវែកវាំងនន សម្លឹងឆ្ពោះទៅខាងក្នុង។ នៅទីនោះគេឃើញអមរាដាដ៏ស្រស់ផូរផង់កំពុងតែចាក់ទឹកតែពីប៉ាន់ទទួលភ្ញៀវដោយទឹកមុខស្រទន់សុភាពរាបសាជានារីខ្មែរនៃគ្រួសារអភិជនពេញដោយក្បួនខ្នាតពិតៗ។

«ប្រាប់ប៉ុន្មានដងហើយឲ្យឈប់និយាយដើមម្ចាស់!»

សំឡេងមីងម៉ាឡាថាឲ្យពូហឿន។

ចិត្រាដឹងថាមីងនេះមកទាន់ចំពេលដែលបុរសតែកុងនិយាយរឿងពិតរបស់ឧត្តមសេនីយ៍ ឱតសាម៉ុនប្រាប់ខ្លួនបានជាត្រូវមីងបន្ទោស។

ទោះយ៉ាងណាពូតែកុងពន្យល់វិញ៖

«ក្មួយប៉ូលិសនេះ ពុំមែនអ្នកក្រៅឯណាគាត់ក្មួយរបស់ឧត្តមសេនីយ៍វិទូ!»

ស្ត្រីអ្នកបម្រើបែរមកសម្លឹងវរសេនីយ៍ត្រីហើយ គាត់ប្តូរទៅជាញញឹម សម្លឹងនាយពីលើដល់ក្រោម។ វាមិនមែនជារឿងចម្លែកទេ ដែលគ្រប់គ្នាឲ្យតែឮឈ្មោះលោកមាហាក់មានអារម្មណ៍ល្អៗឲ្យមកដល់ក្មួយម្នាក់នេះ ហេតុអីលោកមានបន្សល់ទុកនូវឥទ្ធិពលល្អម្ល៉េះហ្ន?

«ឡូយណាស់ ក្មួយប្រុសរបស់ឧត្តមសេនីយ៍សេត វិទូ ថ្ងៃក្រោយល្បីដូចគាត់មិនខាន!»

ស្ត្រីនេះនិយាយសរសើរលើគោក ដូច្នេះធ្វើឲ្យឧត្តមសេនីយ៍ចេះនឹកអៀនអន់ដែរ។ ភ្លាមៗនោះគាត់និយាយបន្ថែម៖

«អ៊ុំចឹងសោះបានជាលោកប្រុស ទុកចិត្តឲ្យក្មួយប៉ូលិសតាមការពារអ្នកនាងដា!»

ចិត្រាញញឹម តែចិត្តពិចារណាស្មុគស្មាញ។

សំឡេងចាស់ៗទាំងពីរបន្តឆ្លើយឆ្លងគ្នា៖

«មីងម៉ាឡាឯងថាមើល៍ បើស្នងការ Roy គ្រាន់មែន មិនមែនលោកប្រុសឲ្យភារៈការពារមកលោកសក្តិបួនទេ!»

ស្ត្រីនៅស្ងៀមមិនមាត់មិនក ធ្វើឲ្យពូហៀងបន្តបន្ថែម៖

«ហើយបើលោកឧត្តមសេនីយ៍ពេញចិត្ត គាត់មកចូលរួមពិធីនេះដែរហើយ មិនមែនគេចទៅកន្លែងធ្វើការបាត់ទេ!»

មីងតវ៉ាវិញ៖

«ឯងមិនឃើញ មានរឿងបាត់ក្មេងស្រីទៀតទេ? បាត់កណ្តាលយប់មិញនៀក បានលោកប្រុសត្រូវចេញទៅ!»

ពូហឿនតវ៉ាវិញវ៉ាវ៖

«ក្តីអីសំខាន់ជាងវេលាល្អរបស់កូនស្រីខ្លួនទៀតនោះ? ហើយស្នងការ Roy ជាស្នងការមួយទាំងមូលរឿងអីថាមានពេលមកសួរប្រពន្ធបាន មិនរវល់បំពេញការងារដែរទៅ?»

ហាក់ទីទើរឆ្លើយនិងពូតែកុងមិនរួច មីងនិយាយបង្វែងដានវិញ៖

«កុំពូកែវិភាគពេក ក្រែងប្រលងចូលប៉ូលិសអត់ជាប់ឯណាហ្អី?»

«ពីណាថាអត់ជាប់? មកបើកឡានឲ្យផ្ទះប៉ូលិសក៏ទុកថាជាប៉ូលិសបានដែរ!»

«អើ! បើឯងដឹងខ្លួនថារស់នៅក្រោមដំបូលផ្ទះមេប៉ូលិស កុំពូកែនិយាយដើមគាត់!»

ពូហឿនហាក់អន់ចិត្តដែរដែលមីងម៉ាឡានៅសុខៗ មកបំបាក់មុខគាត់។ ពូនិយាយតបមិនឈប់៖

«ឬមួយឯងពេញចិត្តស្លុកចង់បានស្នងការRoyមកជាចៅហ្វាយម្នាក់ទៀត?!»

មីងម៉ាឡាមិនមាត់ ហើយងាកសម្លក់ពូហឿនជំនួសឲ្យពាក្យចម្លើយ។ ទោះមិនបានថាអ្វីមួយម៉ាត់ តែទឹកមុខគាត់ក៏ធ្លាក់ជ្រប់មិនបង្ហាញថា គាត់ចង់បានបុរសនេះ មកជាគូអនាគតជាមួយអ្នកនាងស្អាតដូចចន្ទរបស់គាត់នោះឡើយ។

«ម៉ោះក្មួយប៉ូលិស! លោកជំទាវឲ្យនាំក្មួយដើរពិនិត្យជុំវិញបន្ទប់អ្នកនាង និងជុំវិញផ្ទះ!»

ចិត្រាញញឹមងក់ក្បាលទទួលយកការងារជាអង្គរក្សរបស់ខ្លួន...

អ្នកម៉ាឡានាំនាយឲ្យដើរពិនិត្យគ្រប់ជ្រុងជ្រោយរបង បន្ទប់ និងរានហាល។

រួចរាល់គាត់ចាប់ផ្តើមគួរសម៖

«តោះ! មីងមានអាហារពេលព្រឹករៀបជូនលោកក្មួយប៉ូលិស!»

ចិត្រាញញឹមហើយវាចាតប៖

«កុំហៅខ្ញុំខ្ពស់ពេកមីង! ខ្ញុំក៏បម្រើលោកឧត្តមសេនីយ៍ដូចគ្នា!»

«ខុសគ្នាណា៎! ក្មួយបានឡើងសក្តិ ឯមីងគ្មានថ្ងៃបានឡើងសក្តិទេ!»

គាត់ថាហើយញញឹមលួងចិត្ត។ មនុស្សក្នុងផ្ទះនេះមានចរិតឫកពាល្អៗ មើលទៅគួរឲ្យធូរស្រាលចិត្តជាងកាលដែលឃើញអាកប្បកិរិយាដ៏ឆ្មើងកន្ទ្រើងក្រុមគ្រួសារស្នងការ Roy។

ប្រការនេះបើថា អ្នកក្នុងផ្ទះនេះមិនពេញចិត្តខាងកូនកំលោះពិតជាទំនងដែរ។

«តិចទៀតមើលចប់អស់ហើយឆាប់ចុះមកណា មីងមានអីឲ្យញ៉ាំ ថ្មើរណេះហើយ មិនទាន់មានអីចូលពោះច្បាស់ណាស់!»

គាត់រលះរលាំងចុះទៅបាត់ទុកឲ្យប៉ូលិសនៅឈរពិចារណាតែឯង។ បើនៅសុខៗ ឧត្តមសេនីយ៍ ឱតសាម៉ុន  ទូរសព្ទមកហើយប្រាប់ឲ្យលាក់រឿងអលង្ការនាគរាជមានតែគាត់ត្រៀមយកអ្នករងគ្រោះទី៥ធ្វើជានុយស្ទូចរកជនល្មើស???

សូរសំឡេងមនុស្សស្រីសើចមកខឹកៗ ល្វើយៗទាក់ចិត្តអង្គរក្សឲ្យងាកចេញពីភាពសញ្ជឹងគិត។ សូរលាន់ចេញមកពីក្នុងបន្ទប់ដែលមានបង្អួចកញ្ចក់ពិតណាស់។

តើអ្នកណានិយាយគ្នា ហេតុអីមានសូរសំណើចសប្បាយចិត្តរបៀបនេះ?

គេមិនហ៊ានចូលទៅជិត រឹតតែមិនហ៊ាន គិតថាចង់នៅលបស្តាប់អ្វីបន្តព្រោះនេះពុំមែនជារឿងល្អសម្រាប់តួនាទីអង្គរក្ស ប៉ុន្តែត្រចៀកនៅតែឮ៖

«អមរាដា! គេនោះមើលទៅមែនទែនជាមួយឯងម៉ែងហើយ! នាំចាស់ទុំមកចង់រង្គើផ្ទះ!»

ចិត្រាដឹងថាស្រីៗកំពុងនិយាយគ្នាពីស្នងការ Roy។ វរសេនីយ៍ត្រីចាកចេញទៅ ព្រោះមិនចង់ឲ្យមីងម៉ាឡាឡើងមកឃើញខ្លួននៅលបស្តាប់កិច្ចការថៅហ្វាយនាយជាលើកទីពីរឡើយ។

ក្នុងជំហាននីមួយៗ នាយឮសំឡេងអ្នកដែលនិយាយនឹងអ្នកនាងតូចរបស់ខ្លួនវាចាល្វើយៗបន្តមកតាមកម្លាំងខ្យល់៖

«ហើយឯងគិតម៉េចជាមួយគេនោះ?»

**វគ្គ តម្រុយ**

ម៉ោង៩យប់ទៅហើយ ដងផ្លូវស្ងាត់សូន្យ...

អាហារចិញ្ចើមផ្ទល់នៅបើកបម្រើនៅឡើយ ក៏ជាកន្លែងប៉ូលិសទាំងពីរប្រាណបានជួបគ្នាសារសព្វ។

ឯកមានអង្គុយសម្លឹងមិត្តដែលបរិភោគឃ្មមៗ៖

«ផ្ទះធំនោះបង្អត់ឯងមែនអាអង្គរក្សកម្សត់?»

«អត់ទេ តែនៅនោះលេបអីមិនចូល!»

«ហើយអ្អែងហៅអញមកបន្ទាន់មានការស្អី?»

ចិត្រាជូតសម្អាតមាត់ហើយក្រេបទឹក។ ទឹកមុខនាយភ្លឺថ្លា ហាក់បីដូចជាកំពុងស្ថិតនៅក្នុងគម្រោងការគួរឲ្យទាក់ចិត្តអ្វីមួយ។

ឯកមាន នៅសំងំរង់ចាំស្តាប់គេនិយាយ។ វរសេនីយ៍ត្រីចាប់ផ្តើមនិយាយខ្សឹបៗល្មមតែឮពីរនាក់៖

«អញចង់ឲ្យអ្អែងចូលរួមជាមួយអញអាមាន! ដោះស្រាយសំណុំរឿងបាត់មនុស្ស!»

ឯកមានជានាយប៉ូលិសផ្នែកបច្ចេកវិទ្យា។ សំណុំរឿងដែលមិនទាក់ទងនឹងកូដ គឺគេមិនដែលយកមកពិចារណាឲ្យខាតពេលឡើយ។

«អញផ្លាស់មកជួយក្រុមអង្កេតរឿងបាត់ខ្លួនដែរហើយ ឯងស្មានថាអញទំនេរអត់អីធ្វើ? ទាល់តែថ្នាក់លើឱ្យធ្វើបានអញធ្វើ»

ដឹងចិត្តមិត្តច្បាស់ទើបវរសេនីយ៍ត្រីពន្យល់៖

«ស៊ើបក្តីទុកយើងនេះជា ថ្នាក់លើឯងចុះ!»

«អាយ៉ាប់! រឿងអត់ប្រយោជន៍បានវាមកហៅអញ!»

«មិនអត់ប្រយោជន៍ទេ! ពូអញល្បីដោយសារគាត់ស៊ើបក្តីខ្លួនឯងមិនបាច់មានបញ្ហាពីលើទេ!»

«មានន័យថាម៉េច? ក្រែងអ្ហែងមានភារកិច្ចយាមកូនស្រីឱិត សាម៉ុន?!»

«អញមានតម្រុយ!»

«ជឿឯងនាំតែខាតពេលដេក!»

ប៉ូលិសឯកមានស្តីឲ្យទាំងរភ្នែកពិនិត្យពិច័យជុំវិញខ្លួន ក្រែងជួនមានគេតាមដាន។ទោះយ៉ាងណាគេងាកមកវិញសួរបញ្ជាក់៖

«រឿងបាត់ស្រី! កូនអ្នកមានហ្នឹងមែន ដែលអ្ហែងកំពុងនិយាយ?»

«អើ!មានរឿងណាទៀត?»

«អ្ហែងចង់និយាយថា ពីរនាក់យើងហ្នឹង បើកការស៊ើបអង្កេតឯកជន?»

«អើពីរនាក់គ្រប់ហើយ!»

ឯកមានជ្រួញចិញ្ចើមហួសចិត្តហើយនិយាយបក៖

«អាចិត្រ? អ្ហែងដឹងអង្គរក្សគេប៉ុន្មាន? ផ្ទះគេម្នាក់ៗជះលុយប៉ុន្មានហើយទេជាមួយរឿងនេះ? ស្នងការ Royគេសញ្ញាប័ត្រមកពីអង់គ្លេស កូនប៉ូលិសក្នុងដៃរាប់រយនាក់ គេបោះដៃទៅណាក៏មានអ្នកចាំជួយ គេនៅមិនទាន់បំបែកសំណុំរឿងបាន អ្ហែងអាងស្អីចង់យកបុងនឹងគេអ្ហ៎ាអាចិត្រ?»

«អញអាងអ្ហែង!»

ឯកមាននៅស្ងៀមធ្វើភ្នែកភ្លឹះៗ។

ចិត្រាមិនចង់និយាយប្រាប់គេទេថាស្នងការ Roy ដែលគេកំពុងនិយាយដល់តាមពិតមិនបានចំណាយចិត្តទៅគិតរឿងក្តីបាត់ខ្លួនមនុស្សក្រៅក្រុងភ្នំពេញទេ គឺគេកំពុងរកប្រពន្ធឡើងត្រជាក់ចិត្ត។

តាំងចិត្តឈប់ចំណាយគិតពីមនុស្សអត់បានការនោះ គេបញ្ជាក់មកកាន់ក្លើ៖

«បើមានអ្ហែងជួយ អញជឿថារកពន្លឺឃើញ!»

ឯកមានចង់ជេរខ្លាំងណាស់ថា កុំឲ្យចិត្រាអាងលើភាពជាវីរបុរសរបស់ឪពុកមា ហើយមកលេងស្រមៃទាំងថ្ងៃ ព្រោះថាការបាត់ខ្លួនរបស់កូនស្រីអភិជនទាំងបួន ជាសំណុំរឿងកក្រើកមេឃមិនមែនជាឃាតកម្មក្នុងបន្ទប់ស្ងួឪយោតូចមួយដែលអាចនាំឲ្យលោកមាល្បីឈ្មោះកាលពីអតីតកាលនោះទេ។

«នៅចាំបានអត់ ម្សិលមិញអញប្រាប់ថាម៉េច?»

ឯកមាន ដៀងសម្លឹងមិត្ត ដោយក្ដីសង្ស័យ។ សម្ដីចិត្រាកាលពីល្ងាចបានលាន់ត្រឡប់មកវិញក្នុងការចងចាំរបស់នាយ «ម៉េចក៏អញមានអារម្មណ៍ថា ករណីបាត់ខ្លួនទី៤នឹងលេចឡើងក្នុងយប់នេះ?»

ប៉ូលិសកំពូលhack ងាកត្រឡប់មករកមិត្ត។ ចិត្រានិយាយដោយងក់ក្បាល៖

«ហ្នឹងហើយ! និយាយឲ្យស្រួលស្ដាប់ អញមានតម្រុយ!»

ដឹងច្បាស់ថា ទឹកមុខចិត្រាកំពុងតែបង្ហាញជំនឿមុតមាំលើអ្វីមួយ បានជាគេចាប់ផ្ដើមឃាត់៖

«ទៅនិយាយក្នុងឡាន!»

បុរសអ្នកHack បក់ដៃហៅគិតលុយ។

ចូលមកដល់ក្នុងរថយន្តខ្លួនកាលណា ឯកមានចាប់ផ្ដើមនិយាយប្រាប់៖

«ឡានប៉ូលិសមែនទេ! អត់មានស្រូបសំឡេងទេ! និយាយនៅនេះ លាក់ការណ៍បានល្អ!»

គេចេញឡានបណ្ដើរ ស្ដាប់ពួកម៉ាក់និយាយបណ្ដើរ។ ចិត្រាមិនបង្អង់ដៃស្រវាទាញសាក់កាដូមកបើកយកកុំព្យូទ័រចេញមកធ្វើការ ឯមាត់ក៏ចាប់ផ្ដើមពន្យល់៖

«មនុស្សស្រីដែលបាត់ខ្លួនទាំងអស់ មានរយៈពេលឃ្លាតគ្នា៣២ម៉ោងគត់!»

ឯកមានសញ្ជឹងគិតហើយទើបឆ្លើយតប៖

«អ៊ីចឹងបានម្សិលមិញឯងទាយត្រូវថា អ្នកបាត់ខ្លួនទីបួននិងកើតឡើង?»

ជំនួសឲ្យចម្លើយ ចិត្រានិយាយបន្ថែមវិញ៖

«បើយើងចាប់ផ្ដើមធ្វើ ជួនកាលអ្នករងគ្រោះទីប្រាំអាចជួយឲ្យយើងវែកមុខវា!»

ឯកមានជាន់ហ្វ្រាំងបន្ថយល្បឿនហើយងាកមកមើលមិត្ត។ គេដូចជាយល់បណ្ដើរៗពីប្រស្នានេះ។ គេចាប់ផ្ដើមសំណួរជក់ចិត្តៈ

«បើរាប់តាមឯង! គម្លាត៣២ម៉ោង នៅសល់ប៉ុន្មានម៉ោងទៀត?»

«ជាងម្ភៃម៉ោង!»

ចិត្រាឆ្លើយតាមសម្រួលដូចជាអ្វីៗស្ថិតនៅក្នុងការគិតទុកស្រេចបាច់អស់ហើយមុនពេលគេមកកាន់ទីនេះ។

«ប៉ុន្តែគោលដៅ? យើងធ្វើម៉េចដឹងគោលដៅវា? អ្នកទីប្រាំជាអ្នកណាហើយអន្ទាក់នៅកន្លែងណា»

ចិត្រានិយាយផងឈ្ងោកបើកឯកសារផងៈ

«ជនល្មើសគិតថាវារៀបចំស្អាត! សូម្បីមនុស្សបាត់ខ្លួនឯណាក៏គ្មានដាន! ប្រព័ន្ធទាក់ទងទាំងអស់របស់អ្នកបាត់ខ្លួនគ្មានតម្រុយអ្វីប្លែក គួរឲ្យតាមដានបាន! ប៉ុន្តែយើងឃើញរបស់នេះនៅក្នុងប្រវត្តិបាត់ខ្លួនរបស់អ្នកទាំងបួន!»

ឯកមានបែរមករកអេក្រង់ដែលមិត្តកំពុងបង្វិលមកបង្ហាញចំពីមុខ។ គេរវៃភ្នែករកមើលពិនិត្យចុះឡើងយ៉ាងល្អិតល្អន់មុនពេលសួរខ្លីៗៈ

«ស្អីគេ? អញមើលមិនដឹងទេ!»

«ពួកគេទំនងកើតឆ្នាំនាគ ឬមានអ្វីទាក់ទងនិងឆ្នាំនាគ បើមើលលើអលង្ការដែលពួកគេពាក់!»

ឯកមានងក់ក្បាល។ គេអែបទ្បានឈប់។ ដូចការស្មានរបស់ចិត្រា ឯកមានចាប់ផ្ដើមបើកកុំព្យូទ័ររបស់គេ ហើយធ្វើការ។

គេរាវរកប្រវត្តិរូបអ្នកបាត់ខ្លួនជានារីអភិជនទាំងបួនម្ដងម្នាក់ៗ មកស៊ើបមើលថ្ងៃខែឆ្នាំកំណើតហើយងក់ក្បាលទាំងទឹកមុខភ្ញាក់ផ្អើល។

«កើតឆ្នាំ២០០០ទាំងអស់ ឆ្នាំរោង!»

ភាគទី៥

ចិត្រាប្រញាប់សួរវិញ៖

«រកបានទេឆ្នាំ2000មានទារកកើតប៉ុន្មាននាក់ ហើយស្រីប៉ុន្មាន?»

ឯកមាននៅស្ងៀមសញ្ជឹងគិតចុះឡើងមុនពេលឆ្លើយ៖

«រកបានតែស៊ីពេលបន្តិច! សំខាន់តម្រុយនេះទូលាយពេកអត់សូវមានប្រយោជន៍ ចំណុចរួមយើងគួររកឲ្យឃើញល្អិតជាងនេះ! ទីមួយ កើតឆ្នាំរោង២០០០ ហើយសុទ្ធជាកូនអ្នកមាន! គ្រួសារមានខ្លះជាអ្នកច្បាប់ ខ្លះជាអ្នករកស៊ី! ក្រៅពីបាត់ខ្លួនក្នុងរយៈពេល៣២ម៉ោងបន្តគ្នា ហើយកើតឆ្នាំរោងដូចគ្នា មានអីផ្សេងទៀតដែលមានប្រយោជន៍ជាងនេះ?»

ចិត្រាគ្រវីក្បាលហើយឆ្លើយ៖

«គេមិនឲ្យយើងចូលរួម យើងមានព័ត៌មានមិនច្រើនទេ!»

ឯកមានបិទកុំព្យូទ័រហើយដកដង្ហើមធំ៖

«ឯងគួរជម្រាបឧត្តមសេនីយ៍ ឌិត សាម៉ុន! គាត់មានបណ្តាញច្រើន គាត់ដឹងត្រូវធ្វើម៉េច!»

«ប្រាប់គាត់រួចហើយ! គាត់ដឹងមុនយើងប្រាប់ទៀត! តែអញជឿថាគាត់បំបែកក្តីនេះមិនកើតទេ!»

ឯកមានជ្រួញចិញ្ចើមខ្សឹបសួរវិញតិចៗព្រោះភ័យ៖

«ស្អីគេ? បើថាដល់ទៅមេព្រហ្មទណ្ឌហើយធ្វើមិនបែក អ្ហែងជាមួយអញនេះអាងស្អីទៅធ្វើ?»

ចិត្រាមិនខ្វល់និងការវាយតម្លៃរបស់មិត្ត នាយពន្យល់វិញក្នុងជំនឿចិត្តមួយផ្សេង៖

«ស្តាប់អាមាន! ជនល្មើសវាដូចជាកំពុងតែលេងអីម្យ៉ាង! រយៈពេលឃ្លាតគ្នា៣២ម៉ោង វាដូចជាចង់ឲ្យសញ្ញាអីមួយទៅប៉ូលិស! ចំណែកអលង្ការនាគ ឬមនុស្សឆ្នាំនាគ អាចថាជាតម្រុយសំខាន់ផ្សេង ទៀត ប៉ុន្តែវាប្រហែលកំពុងឃ្លាំមើលប៉ូលិសវិញយ៉ាងជាប់! នៅកន្លែងដែលយើងមើលវាមិនឃើញ តែវាមើលយើងឃើញ! ចំណែកយើងពីរនាក់មិនមាននៅក្នុងក្រុមដោះ

ស្រាយសំណុំរឿង ជួនកាលនេះជាអំណោយផល ដែលពួកដៃដល់វាអាចនឹងមើលរំលងយើង!»

ឯកមាន រឹតតែស្តាប់នាយរឹតតែស្មុគស្មាញ។

គេគិតចុះឡើងហើយសួរវិញ៖

«យើងទៅរាវរកអ្នករងគ្រោះទី៥នៅកន្លែងណា នៅឆ្នាំ២០០០មនុស្សកើតរាប់ម៉ឺននាក់ ហើយអ្នកហ្នឹងមកពីក្រៅប្រទេស ឬមួយគេលាក់អាយុកំណើតពិត យើងធ្វើម៉េចដឹង?»

«ខ្ញុំយល់ថា យើងគួរងាកទៅជ្រុងផ្សេង! សំណួរសំខាន់មិនមែនថាមនុស្សឆ្នាំនាគណាមួយដែលជាមនុស្សត្រូវបាត់ខ្លួនបន្តទេ ប៉ុន្តែ តើគេយកមនុស្សឆ្នាំនាគទៅណាហើយទៅធ្វើអី?»

ឯកមានហួសចិត្ត គេនិយាយឌឺមិត្តវិញទាំងដៃលូកបើកកុំព្យូទ័រ៖

«បើឯងបានជួបអាជនល្មើសហ្នឹង ជួយសួរវាហើយយកមកប្រាប់គ្នាវិញផង!»

ដឹងត្រូវគេឌឺ ចិត្រានៅស្ងៀមមិនមាត់។

ឯកមានថាឲ្យបន្ត៖

«អើ ធ្វើម៉េចបើជ្រុងរបស់ឯងសួរសុទ្ធតែមូលហេតុ ហេតុអីបានចាប់? អាណាឆ្លើយកើតក្រៅពីជនល្មើស!»

«គ្រប់កាយវិការ សកម្មភាពតែងមានបង្កប់ហេតុ! យើងអាចពិចារណាពីផលដែលបានមកពីហេតុជួនកាលអាចដឹងតំណាសេចក្តីបាន!»

«អញស្តាប់ឯងបកស្រាយរឹតតែងងឹតទៀតហើយអាម៉ាក!»

ចិត្រាដកដង្ហើមធំ៖

«ស្តាប់ហើយឯងថាយើងរើរវាយក៏បានអាមាន! ប៉ុន្តែឯងគិតមើល បើចាប់កូនអ្នកមានជំរិតម៉េចក៏មិនឃើញទារលុយ? ហើយបើចាប់ក្នុងចេតនាផ្សេង ម៉េចក៏ចាំបាច់ឆ្នាំរោង?»

ដៃរបស់សក្តិបួន ឯកមាន បើកកុំព្យូទ័របណ្តើរ និយាយវែកញែកតបមកកាន់មិត្តវិញបណ្តើរ៖

«អញវិញគិតពីជ្រុងផ្សេង! គិតរបៀបឯងនាំតែវង្វេងវិលវល់នៅហ្នឹង! គិតពីអ្នករងគ្រោះគ្រាន់បើជាងគិតពីអាអ្នកដៃដល់! ព្រោះវានៅឯណាមិនដឹង យើងស៊ើបអង្កាល់ចេញ? អញចង់ដឹងថាមុនពេលកើតហេតុអ្នកទាំងបួនហ្នឹងពិតជាមានសល់ចំណុចរួមអីផ្សេងទៀត? ដូចជា...»

«ទៅកន្លែងណា ទាក់ទងអ្នកណា ហើយធ្វើអីខ្លះ???»

ឯកមាន ងក់ក្បាលដៃនៅតែធ្វើការញាប់ស្មេរ។ គេសរសេរកូដជាច្រើនដែលចិត្រាមើលមិនយល់តែដឹងថាគេកំពុងធ្វើដោយប្រុងប្រយ័ត្ន។

វរសេនីយ៍ត្រីនិយាយបន្តទៅកាន់មិត្តៈ

«ដូចប្រាប់មុននេះថា ប្រព័ន្ធទាក់ទងទាំងអស់របស់អ្នកបាត់ខ្លួនគ្មានតម្រុយអ្វីប្លែក Facebook ទូរសព្ទ អ្វីគ្រប់យ៉ាងគ្មានដានថា នាងចេញទៅណា ទៅរកអ្នកណា នៅណាទេ! ប៉ុន្តែសម្រាប់យើង លើកលែងតែពួកគេចេញខ្លួនឯង ដោយគ្មានអ្នកចាប់ បើសិនជាមានលើកលែងតែអ្នកនោះជាខ្មោចមិនមែនមនុស្សបានគ្មានសល់ដាន!»

«អ្វែងទុកពេលឲ្យអញ!»

ចិត្រាងក់ក្បាល ឯកមាននិយាយបន្ថែមៈ

«មួយយប់នេះច្បាស់ជារកឃើញអ្វីខ្លះមិនខាន!»

ចិត្រាងក់ក្បាលបន្តហើយបិទកុំព្យូទ័រខ្លួនឯងចោល។

**វគ្គ តួនាទីអង្គរក្ស**

ព្រហាមស្រាងៗ...

«ព្រលឹមម៉េះកូន? បបរមិនទាន់រីកគ្រាប់ផង  ក្រែងយប់មិញប្រាប់ថាចង់បបរសាមចូក!?»

ចិត្រាពាក់ស្បែកជើងប្រញាប់ប្រញាល់ ហើយឆ្លើយតបមុនពេលលូកដៃរកសោម៉ូតូៈ

«ទុកល្ងាចឲ្យកូនបានមួយចានផងម៉ាក់! កូនត្រូវទៅហើយ!»

អ្នកម្ដាយសម្លក់ ហើយសួរបញ្ឆិតបញ្ឆៀងៈ

«ល្ងាចឬមួយអធ្រាត្រ??»

គេឱនមកញញឹមយកចិត្តម្ដាយហើយខ្សឹបៈ

«ជីវិតអង្គរក្សគេអ៊ីចឹងហើយម៉ាក់!»

ម្ដាយមិនមាត់មាត់ក ប៉ុន្តែអ្វីម្យ៉ាងដែលគាត់សង្កេតឃើញគឺថា ហេតុអ្វីបានជានាយទំនងជាមានស្ថានភាពសប្បាយរីករាយម្ល៉េះ?

«ឬមួយក៏កូនស្រីគេម្នាក់នោះស្អាតខ្លាំង បានជាធ្វើអង្គរក្សពីព្រលឹមក៏មិនរអ៊ូ?»

ម្ដាយនិយាយទូរសព្ទទៅសួរនាយ ឯកមានពេលដែលកូនចេញទៅបានបន្តិច ចំណែកចម្លើយដែលបានមកវិញគឺថាៈ

«អូ! យប់មិញហូបអីតាមផ្លូវជាមួយគ្នា ភ្លេចសួរវាថាលង់ស្នេហ៍ម្ចាស់ហើយអី?»

ចម្លើយរបស់ឯកមាន ធ្វើឲ្យម្ដាយញញឹមបិទមាត់មិនជិត។ គាត់ចាប់ផ្ដើមស្រដីតបទៅកាន់ខ្សែទូរសព្ទម្ខាងទៀតៈ

«កាលពីកូនចិត្រកើតមក គ្រូទាយវាថានឹងបានប្រពន្ធជាស្រីគ្រប់លក្ខ កូនអ្នកជាមានពូជមានអម្បូរ!»

ដឹងថាស្ត្រីនេះកំពុងស្រមៃចង់បានកូនប្រសាជាអ្នកនាង ឯកមានបង្អាប់វិញភ្លែតៈ

«អ្នកមីង! ខ្ញុំតាំងពីតូចមកប្រាថ្នាថា ជាតិនេះស្រលាញ់ប៉ះតែស្រីអ្នកមានកប់ស៊េរី ស្អាតដូចដួងតារាហើយមានប្រាជ្ញាដូចនាងអមរាដែរ!»

«អមរាជាមែនអត់?»

គាត់ញញឹមថាឲ្យសក្តិប្អូន ឯកមានទាំងមិនដឹងទេថា នាយទូរសព្ទមកពេលនេះ គឺចង់ប្រាប់រឿងយ៉ាងសំខាន់មួយដែលបានរុករកពេញមួយយប់ទៅហើយ។

នៅឯណោះបុរសអង្គរក្សមកដល់ផ្ទះម្ចាស់ស្រីនៅត្រឹមម៉ោង៦ព្រឹក។

«ព្រឹកម៉េះក្មួយប៉ូលិស!»

ពូហឿនហាក់រីករាយពេលបានឃើញនាយជាថ្មី។

ពេលនាយរុញម៉ូតូចូល គាត់បិទទ្វារផងនិយាយបូរបាច់ផងៈ

«អ្នកនាងអមរាជាត្រូវចេញទៅប្រលងភ្លេងព្រឹកនេះ! តាមពិតឧត្តមសេនីយ៍ហាមមិនឲ្យចេញទៅណាដែរ តែពេលនេះជាការប្រលងជ្រើសរើសជើងឯកទៅបរទេស ទៅប្រលងដល់អេស្ប៉ាញទៀត បានជាលោកមិនដាច់ចិត្តហាម!»

«ហេតុអីបានជាគាត់រៀនភ្លេង?»

«អ្ហឹយ លោកក្មួយ! ពួកកូនអ្នកមាន ស្អីក៏រៀនដែរ នេះ ពូមិនទាន់ប្រាប់ពីការ៉ាតេដូផង!»

គេចំហមាត់។

ពូហឿនរាដែបញ្ឈប់កុំឱ្យគេគិតៈ

«តែគាត់រៀនមិនចេះទេខាងវាយតប់! គុនដាវ! វ៉ៃបុករៀនទាំងអស់មិនឃើញវ៉ៃអ្នកណាបានម្នាក់សោះ!»

«អ្ហូយ! ស្មានតែសុភាព?»

ពូហឿនមិនទាន់បានតបផង សំឡេងមនុស្សដែលចិត្រាមិនចង់ឮមិនចង់ជួបលាន់មកសាជាថ្មីៈ

«និយាយដើមចៅហ្វាយហ្នឹង ឯងដឹងពីវិន័យអង្គរក្សហើយឬនៅ?»

សរសើរថាខ្លួនមកបំពេញកិច្ចការបានរហ័ស ដឹងអីមនុស្សឆ្អឹងទទឹងកម្នាក់នេះរឹតតែមកជំទាស់មកទើសបានរហ័សជាងការគិត គឺក្រោកពីយល់សប្តិមកធ្វើជាមាបានតែម្តង។

ចិត្រាបង្ខំចិត្តឈរត្រង់ខ្លួនលើកដៃគោរព។

«សូមគោរពទាន!»

ស្នងការ Roy កំពុងតាំងខ្លួនដូចជាម្ចាស់ផ្ទះ ដូចជាកូនប្រសាឧត្តមសេនីយ៍ ឱិត សាម៉ុនពិតៗ។

គេប្រកាន់ទឹកមុខស្មើ ធ្វើឲ្យពូហឿនដើរហួសទៅដោយមិនហ៊ានមកលូកមាត់កអ្វី ទុកឲ្យបុរសនេះ មានឱកាសបញ្ចេញអំណាចជានាយចៅហ្វាយដែលធ្លាប់តែគ្មានអ្នកណាហ៊ានជំទាស់។

គេក្រពាត់ដៃនិយាយសោះអង្គើយៈ

«ស្ដាប់ឲ្យទាន់វិន័យសម្រាប់អង្គរក្សផ្ទះនេះ! មួយ មិនឲ្យដើរទន្ទឹមចៅហ្វាយ មិនឲ្យអង្គុយពេលបំពេញការងារ!»

«បាទទាន!»

ឃើញវរសេនីយ៍នៅគំនាប់គោរព គេមិនបានឲ្យសម្រួលឥរិយាបថទេ រឹតខែងរ៉ែងចេញបញ្ជាបន្ថែម៖

«ហាមខ្ជិល! ហាមនិយាយទូរសព្ទ ហាមរវេក្នែកទៅកន្លងផ្សេង! ចៅហ្វាយនៅត្រង់ណា ត្រូវនៅត្រង់ណោះ!»

«បាទទាន!»

«មិនទាន់ចប់ទេ! ពេលឈរការពារ មិនឲ្យឈរពីមុខ មិនឲ្យនៅពីក្រោយ មិនឲ្យនៅចំហៀងកៀកជាងមួយម៉ែត្រ!»

«បាទទាន!»

នាយស្រែកឮៗព្រោះកន្ទុយភ្នែកឃើញឧត្តមសេនីយ៍ ឌិត សាម៉ុន កំពុងហាត់ប្រាណនៅបន្ទប់កញ្ចក់ជាន់ខាងលើ ចិត្តមួយបែរបន់ស្ងាត់ៗថា «ឧត្តមសេនីយ៍ លោកមើលចុះ ពេលនេះមនុស្សដែលលោកទុកចិត្តប្រគល់កូនស្រីឲ្យរក្សាការពារកំពុងត្រូវបានធ្វើបាបដោយអនាគតកូនប្រសាលាក់ពុតរបស់លោក!»។

«អ្ហូយ! ក្បួនអង្គរក្សអីក៏ពិបាកខុសគេម៉េះហ្នឹង?»

សំឡេងស្រួយស្រេះ លាន់មកក្បែរចំណតឡានបានន័យថាម្ចាស់សំឡេងមកដល់យូរហើយគ្រាន់តែមិនបង្ហាញខ្លួន។ ពេលនេះស្នងការ Roy ផ្លាស់ប្តូរឥរិយាបថ ទៅជាញញឹមញញែមស្លូតបូត។

ចិត្រានៅជាប់គោរពមិនអាចងាកទៅណាបានឡើយ ទើបបានមិនអាចឃើញនារីម្ចាស់សំឡេងច្បាស់ តែនាងនិយាយមកជួយបន្ត ដើម្បីជួយដោះស្រាយនាយនៅនឹងមុខបុរសប្រើអំណាចផ្ដាច់ការនេះ៖

«ហើយបងឯងនៅគោរពយូរម៉េះ? មិនដឹងអមរាជាសួររកឲ្យជួយឡើងទៅលើកអីវ៉ាន់ទេ?»

បានឱកាសនាយទម្លាក់ដៃហើយឱនកាយចាកចេញពីមុខស្នងការដែលមិនទាន់បានធ្វើបាបបុរសអង្គរក្សអស់ចិត្តទៅតាមផែនការ។

«ហើយបងឯងបញ្ហាគាត់អីបញ្ហាម៉េះបង Roy?»

នាងទំនងជាមិត្តរបស់អមរាដាដែលខ្លួនបានឮសំឡេងកាលពីម្សិលនៅបន្ទប់ខាងលើ។

ពេលដើរចេញបណ្ដើរ ត្រចៀកវររសេនីយ៍ត្រីនៅស្ដាប់ឮសូរសម្ដីពួកគេជជែកគ្នាបណ្ដើរ។ នាយ Royដូរឥរិយាបថទៅជាសុភាពបុរសភ្លាមៗបញ្ចេញសំឡេងឡើងស្រទន់៖

«បងមានទៅបញ្ហាអី! ក្មេងគ្នាមិនដឹងក្បួនបានជាបងមកចំណាយពេលជួយប្រាប់ ខ្លាចបម្រើអមរាដាអត់បានកើតជាការអី! ហើយផានូមករកអមរាដាពីព្រឹកម៉ង! មានការអីសំខាន់? ប្រាប់បងផងបានអត់?»

«អត់អីទេ! ខ្ញុំនិងអមរាដាប្រញាប់សមភ្លេង!»

ចិត្រាដឹងជាស្រេចហើយថានារីនេះឈ្មោះផានូ ហើយនាងក៏មើលទៅមិនពេញចិត្តស្នងការRoyប៉ុន្មានដែរ ចំណែកស្នងការនេះវិញ ឃើញមនុស្សស្រីស្អាតកាលណាទម្លាក់ចរិតធ្វើពុតជាសុភាពបុរសពេញទីមិនរើសថាពួកម៉ាកគូដណ្ដឹងឬអ្វីក៏ដោយ។

មកដល់ជាន់ខាងលើ នាយនៅទីទើរ ព្រោះមិនឃើញអមរាដាចេញក្រៅប្រើឲ្យយកសម្ភារៈភ្លេងចុះដូចផានូបានបង្គាប់ពីខាងក្រោមសោះ នៅដើរចុះឡើងរង់ចាំ។

ផានូដែលឡើងមកតាមក្រោយ ឃើញលោកសក្តិបួនដែលកំពុងធ្លាក់ខ្លួនជាអង្គរក្សការពារហើយមក ដើររង់ចាំចុះឡើងជុំវិញបរិវេណជាន់នេះ នាងនឹកអស់សំណើចក៏និយាយប្រាប់៖

«ហើយបងឯងនៅចាំអី! ខ្ញុំកុហកទេ! អមរាដាមិនប្រើអីឯណា ខ្ញុំចង់ឲ្យបងឯងគេចៗឲ្យផុតពីស្នងការRoy ស្អីគេនោះ! ជ្រេញអាគាត់ហ្នឹងដល់ហើយ!»

ផានូថាចំៗឮៗ ធ្វើឲ្យចិត្រាអើតមើលឆ្វេងស្ដាំនឹកភ័យជំនួសខ្លាចថាស្នងការ Roy ដើរមកឮ។ យល់ចិត្តនាយ នារីអភិជនសើចប៉ប្រិមហើយនិយាយប្រាប់បន្ត៖

«បងឯងភ័យអី? ស្មានថានាយនោះបានឡើងមកម្ដុំៗណេះហ្អី? មានតែអង្គរក្ស ដូចបងឯងទេចេញចូលជាន់នេះបាន! »

ចិត្រាញញឹមដឹងគុណនាង។

នារីនេះពិតជាមានសម្រស់មិនចាញ់មិត្ត គ្រាន់តែរាងមាត់ដាចហើយឆ្មើមជាងបន្តិច តែក៏មានចរិតស្មោះត្រង់គួរឲ្យចូលចិត្ត។ នៅមិនទាន់ដឹងនៅឡើយដែរថា តើនាងជាកូនចៅលោកណាបានជាអាចមកស្និទ្ធស្នាលចុះឡើងផ្ទះកូនស្រីឧត្តមសេនីយ៍ថ្មើរណេះស្រេចតែនឹងចិត្ត ហើយក៏ថែមហាស៊ីបញ្ឆិតបញ្ឆៀង មិនខ្វីក្រែងលោកស្នងការ Roy អីបន្តិចផង។

«បងឯងចុះទៅក្រោមវិញបាន ហើយនៅឆ្ងាយៗពីម្នាក់ហ្នឹងទៅកុំឲ្យគេបង្កាប់បញ្ជាធ្វើបាបបានទៀត!»

«បាទទាន!»

នាងញញឹមចូលបន្ទប់មិត្តបាត់ទុកឲ្យវរសេនីយ៍ត្រីរកផ្លូវដកថយ។

ទោះយ៉ាងណា គេឮសំឡេងនាងលាន់មកកណ្ដាលបរិយាកាសស្ងាត់៖

«អង្គរក្សឯងរាងដូចប៉ូលិស!»

នាយឮហើយបង្អង់ស្ដាប់។

ចិត្តមួយចង់ដឹងថាពួកគេនិយាយថាយ៉ាងណាពីខ្លួន ហើយចិត្តមួយទៀតចង់ឮសំឡេងកល្យាណីម្ចាស់បន្ទប់ថា តើនាងមានចរិតកាចឆ្មើមដូចនារីឈ្មោះផានូដែរឬអ្វី?

«គេប៉ូលិសហ្នឹងហើយ! នៅរាងដូចអីទៀត?»

នាងតបទៅមិត្តបែបនេះ ហើយតបយ៉ាងស្រទន់ធ្វើឲ្យចិត្តបុរសប្រែទៅជាទន់ បបូរមាត់បែរជាញញឹម ជើងក៏អស់កម្លាំងនឹងបន្តដើរទៅមុខ។

មិនតែប៉ុណ្ណោះ នារីឈ្មោះផានូបន្ថែមឡើងមកវិញផង៖

«ថាប៉ូលិសៗមែន! នែ ដឹងអត់គេសង្ហាណាស់ដែរតើ!!»

ប្រុសណាមិនកើតក្ដីរំភើបភ្លាមៗ ពេលឮថាស្រីៗកំពុងលបសរសើរពីក្រោយខ្នងបែបនេះ។

ដោយឱនមើលរាងកាយខ្លួន វរសេនីយ៍ត្រីភ្លេចអស់ក្ដីធុញថប់ដែលត្រូវជួបស្នងការកំហូចកាលពីមុននេះហើយភ្លេចថាត្រូវចាកចេញទីនេះ។

«ហើយម៉េច?!»

សំឡេងស្រទន់របស់អ្នកនាងអមរាជាសួរចំអកបង្អាប់ទៅពួកម៉ាកនាងវិញ។

ផានូក៏មិនទេញទាល់ នាងឆ្លើយភ្លាម៖

«មានម៉េច! បើឋានៈគេល្អតែបន្តិចយើងអាចនឹងពិចារណាគេ!»

ព្ពួកម៉ាកនិយាយចប់កាលណានាងក៏សើចកក្អឹក។ សើចអស់ចិត្តអមរាជានិយាយបញ្ជោះ៖

«នែស្រីមាសប្រាក់យសសក្តិ! ខាងក្រោមមានប្រុសមានឋានៈ ហើយមានលុយច្រើន ម្នាក់កំពុងដើរចុះឡើងគួរឲ្យជ្រេញកណ្តាលផ្ទះយើង! ឯងយកចុះណ៎ាសូមអញ្ជើញ!»

«ស្នងការ Roy ហ្អី?»

ផានូសួរវិញចំអក ធ្វើឲ្យចិត្រាដែលកំពុងឈរលបស្តាប់កណ្តាលកាំជណ្តើរនឹកភ្នកដល់ចរិតដ៏លាក់ពុតនៃបុរសនោះ។

«ស្នងការកំហូច! សមមុខឯងហើយដែលមានស្រីៗស្អប់ ហើយបញ្ចេញកំហឹងជំនួសយើង ឯងសាងអីបានហ្នឹងមែន!»

សំឡេងផានូ តបតមិនឲ្យចាញ់មិត្តមួយម៉ាត់ណាឡើយ៖

«ហើយគេមកដណ្តឹងអ្នកណា? ត្រៀមខ្លួនធ្វើលោកជំទាវស្នងការឲ្យតែល្អទៅអ្នក មិនបាច់លើកមកខាងណេះឡើយ! ខាងណេះរកមនុស្សមានឋានៈ មានលុយ តែក៏រើសចរិតដែរវើយ! អត់ជាប់ជម្រើសទេលំដាប់ហ្នឹងនោះ!»

«មិនបាច់មកនិយាយទេនាង! យើងអមរាជានេះស្លាប់ក៏មិនយកម្នាក់ហ្នឹងដែរ!»

សម្តីនាងធ្វើឲ្យចិត្រាបើកភ្នែកធំៗម្នាក់ឯងនៅកណ្តាលគេហដ្ឋានស្ងាត់ច្រៀប។

«ដល់ម្លឹងផងមនុស្សស្រី? មិនពេញចិត្តគេសោះ ហើយឲ្យគេនាំឪពុកម្តាយមកធ្វើអី?»

គេល្បួចគិតដូច្នេះ តែក៏រីកថ្លើមពេលដែលដឹងថាព្រហ្មលិខិត កំពុងជួយសងសឹកឲ្យខ្លួនយ៉ាងសក្តិសមណាស់ហើយ។ សូម្បីព្រឹកម្សិល អ្នកបម្រើចាស់ៗនៅជាន់ខាងក្រោមក៏ឆ្លោយមាត់ប្រាប់

ថា គ្មានអ្នកណាពេញចិត្តបុរសមកពីអង់គ្លេសម្នាក់នេះដែរ បានន័យថានាយ Roy នេះចរិតជួយមិនបានតែម្តង។

ពីកន្ទុយភ្នែក វរសេនីយ៍ត្រីក្រឡេកឃើញអ្វីម្យ៉ាងគួរឲ្យចាប់អារម្មណ៍។

នោះគឺឯកសារមួយសំណុំលើកូនតុមាត់ជណ្តើរ ដែលលំអដោយចូផ្កា។ ទីនេះមិនសមកន្លែងទុកឯកសារទេ មានអ្នកណាម្នាក់ភ្លេចវានៅទីនេះពិតណាស់ ហើយដែលរឹតតែសំខាន់គឺមានសរសេរពាក្យថា «អ្នកបាត់ខ្លួនទាំងបួន»។

ដូចរកឱសប្រទះឈើងាប់។

កំពុងតាំងចិត្តថាស៊ើបក្តីកសាងឈ្មោះសាកល្បងដោះប្រស្នាដោយចិត្តឯង ពេលនេះមានរបស់ជួយនៅនឹងមុខចាំដល់អង្គាល់ទៀតមិនលើកយកមកឆែកមើល។

ប៉ូលិសប្រាកដជារកបានតម្រុយជាច្រើន ទាក់ទងនឹងសំណុំរឿងនេះ ហើយអ្នកដែលយកវាមកប្រាកដជាឧត្តមសេនីយ៍ ឱត សាម៉ុន មេព្រហ្មទណ្ឌដែលដឹកនាំបំបែកក្តី។

អម្បាញ់មិញនាយឃើញគាត់នៅហាត់ប្រាណខាងលើ? គាត់ជាអ្នកភ្លេច?

ប៉ុន្តែតើសមដែរទេ ដែលឯកសារសំខាន់បែបនេះ យកមកទុកកណ្តាលផ្លូវ? ឬមួយដូចសម្តីអ្នកនាងផានូ អះអាងថាមិនងាយមានអ្នកណាមានសិទ្ធិឡើងមកទីនេះ? តែ... ឬមួយក៏ម្ចាស់ឯកសារមានចេតនាឲ្យយើងមើល?

នាយបើកភ្នែកមូលក្លុំមុតថ្លា ហើយងើយសម្លឹងទៅជាន់ខាងលើ។ គ្មានសញ្ញាថាមេព្រហ្មទណ្ឌបញ្ចប់ការហាត់ប្រាណហើយដើរចុះមកនៅឡើយទេ។ ប៉ុន្តែ អ្នកណាហ៊ានថ្លើមធំយករបស់នេះមកឆែកមើលទៅ? នាយងាកឆ្វេងស្តាំហើយកាត់ចិត្តផ្តាច់អារម្មណ៍ចុះជណ្តើរត្រឹកៗ ចោលរបស់ដែលកំពុងទាក់ចិត្តទាក់អារម្មណ៍។

មកដល់ជាន់ក្រោម នៃបន្ទប់ធំដែលស្ងាត់ល្ងឹងទូរសព្ទចាប់ផ្តើមរំញ័រ។ គេលើកមកពិនិត្យដឹងថាជា សក្តិបួនឯកមាន មិត្តរបស់ខ្លួន។ ម្នាក់នេះទំនងជារកឃើញអ្វីម្យ៉ាងប្រាកដណាស់។ វរសេនីយ៍ត្រីគិតហើយ ក៏ថយទៅជ្រុងម្ខាងលើកយកមកស្តាប់។

«អាឡូ! យើងនិយាយមិនបានច្រើនទេ! មានអីឆាប់និយាយឲ្យលឿនអាមាន!»

សំឡេងក្តីដែលបានរូងភ្នែកអស់មួយយប់ ដោយសារការងារស្រាវជ្រាវលាន់មកវិញ៖

«អញរកឃើញចំណុចសំខាន់បី!»

ចិត្តវរសេនីយ៍ត្រីហោះហើរទៅដល់ស្នងការភ្លេចគិតថា ពេលនេះខ្លួនកំពុងមានកាតព្វកិច្ចអ្វីនៅទីនេះ។ ឃើញស្ងាត់គេតឿនភ្លាមទាំងប្រឹងខ្សឹបណែនពេញទ្រូង៖

«អ្អែងមិននិយាយមកអានេះ? ស្មានតែមានពេលច្រើនណាស់អ្អេស៎!?»

នាយសក្តិបួនឯកមាន តវ៉ាវិញ៖

«អញចំណាយពេលពេញមួយយប់ឲ្យវា ឥឡូវបើគ្មានពេលគ្រប់នឹងស្តាប់ អញឈប់និយាយក៏បានអាចិត្រ!»

ដឹងថានាយ ឯកមាន កំពុងកាច់វិញ ចិត្រាទប់ចិត្តរកវិធីមកប៉ះប៉ូវ៖

«អើ! បើអ្អែងមិនចង់បានព័ត៌មានពីស្រីស្អាត ចិត្តល្អ ហើយមានទៀត អ្អែងផ្តាច់ទូរសព្ទចុះអាមាន!»

ត្រូវចំចំណុចខ្សោយ រកកាច់បំបាក់ក្តីក៏មិនកើត ព្រោះស្រីស្អាតហើយមានទ្រព្យ គឺជាបំណងដ៏ធំជាងគេក្នុងជាតិនេះសម្រាប់សក្តិបួនឯកមាន អ្នកណាក៏ដឹង។ អ៊ីចឹងហើយបានជានាយនិយាយតបវិញជាមួយជាតិ ចិត្រា៖

«បាន! ទុកថារួចខ្លួន!»

«ឆាប់និយាយម៉ោអ្ហា!»

«ទីមួយ ស្រីៗបាត់ខ្លួនទាំងបួន សុទ្ធតែមានកំណត់ហេតុកុម្ម៉ង់ខោអាវដេកយប់ដែលថ្លៃ និងសិចស៊ីបំផុត មុនពេលកើតហេតុមួយអាទិត្យ!»

ចិត្រាបើកភ្នែកគ្រលួង។ ចិត្តនាយចាប់ផ្តើមគិតដល់រឿងផ្សេង ក៏ជាចំណុចមួយដែលគេបានដឹងតែភ្លេចសម្គាល់។ «អ្នកដែលបានឃើញ ពិនណា ក្រោយគេ គឺលេខារបស់នាងឈ្មោះ ដារីដ! សាក្សីនិយាយថានាងពិនណាចេញពីផ្ទះជាមួយសម្លៀកបំពាក់វែងរបៀបពិធីសមោសរគ្រឿងអលង្ការជាច្រើនសែនដុល្លារហើយមានអង្គរក្ស៤នាក់តាមពីក្រោយ! ពេលនេះពួកអ្នកការពាររួមទាំងតៃកុងឡាននាងផងក៏ទាក់ទងមិនបានដូចគ្នា! »

នេះជាសម្ដីរបស់ស្នងការ Roy ដែលបាននិយាយនៅនឹងមុខឧត្ដមសេនីយ៍បីនាក់ទៀត នៅពេលដែលខ្លួនត្រូវបានកោះហៅចូលស្ដាប់ដំបូង។

ចិត្រាធុញទ្រាន់ចិត្តជាមួយព័ត៌មានទាំងនេះ រហូតដល់របូតមាត់រអ៊ូ៖

«ឬមួយ ស្រីៗទាំងនេះ មុនបាត់ខ្លួន បានរៀបគម្រោងចេញទៅជួបអ្នកណាម្នាក់ ជាមនុស្សប្រុស?»

ភាគទី៦

ស្នូរជើងលាន់មកពីក្រៅ...

បើឲ្យស្នងការដឹងពីប្រធានបទដែលខ្លួនកំពុងនិយាយនិងមិត្ត មុខតែវរមិនខាន។ គិតហើយកាលណា នៅក្នុងកាលៈទេសៈដ៏តក់ក្រហល់ នាយប៉ូលិសថយទៅជ្រុងម្ខាងផ្ទះទាំងទូរសព្ទមិនទាន់ចុចបិទ។

បានឆ្ងាយពីសម្រឹបជើងកាលណា ចិត្រាចាប់ផ្ដើមខ្សឹប៖

«មានអីសំខាន់ជាងហ្នឹងទៀតអត់? ឆាប់និយាយមក! អើ! ហើយចុះអាពីរចំណុចទៀត?»

ចិត្រាមិនទាន់ឮការឆ្លើយតបពីចុងម្ខាងថាយ៉ាងណាផង សំឡេងនៅក្រៅទូរសព្ទលាន់មកល្វើយតាមខ្យល់៖

«អ្នកនាងអមរាដាឲ្យខ្ញុំយកមកល្វាចមិញ ប៉ុន្តែទើបនឹងហើយ បានជាមកទាំងព្រឹក!»

សំឡេងដែលគេស្គាល់ថាជាមីងម៉ាឡាតបវិញ៖

«ជារបស់អ្វីទៅក្មួយ?»

«ជារ៉ូបសមោសរណាមីង!»

ចិត្រាស្រាប់តែជក់ចិត្តនឹងពាក្យថា «រ៉ូបសមោសរ»។

អ្នកនាងពិនណា ជនរងគ្រោះទី៣ បានបាត់ខ្លួនទៅជាមួយឈុតចូលរួមពិធី។ ចំណុចនេះគឺជាអ្វីដែលខ្លួនទើបនឹងនឹកឃើញចាប់អារម្មណ៍។ ហេតុអីកូនស្រីផ្ទះនេះ បានកុម្ម៉ង់របស់នេះ មកដល់ទាំងព្រហាម? ជូនគ្នាម្លេះ?

សំឡេងអ្នកម៉ាឡា លាន់មកកាត់ផ្តាច់ការគិតស្វាត់របស់លោកសក្តិបួន៖

«នៅចាំបន្តិច មីងទូរសព្ទទៅជម្រាបអ្នកនាងដាឲ្យ!»

ឆ្លៀតឱកាស នាយថយកាន់តែឆ្ងាយទៅក្នុងគុម្ពោតផ្កាក្បែរសួន ហើយឆ្លៀតខ្សឹបសួរមិត្ត៖

«អញមានអារម្មណ៍មិនស្រួលស្រួលម៉េចមិនដឹងទេអ្ហា! ម៉េចក៏នៅសុខៗនាងកុម្ម៉ង់អាវរ៉ូបវែងម្នាក់ទៀតហើយ?»

សក្តិបួនឯកមានសួរបកមកវិញ ទំនងដូចជាខឹងដង៖

«សំខាន់មានកុម្ម៉ង់អាវដេកយប់អត់?»

វរសេនីយ៍ត្រីតបវិញទាំងឆក់កណ្តៀត៖

«មិនទំនងសោះអ្ហា! កូនឧត្តមសេនីយ៍មានចរិតសុភាពខ្លាំងណាស់! នាងមិនធ្វើដូចពួកកូនអ្នកមានផ្សេងៗទេ!»

សក្តិបួនឯកមានសើចកក្អឹកពេញទំហឹង ធ្វើឲ្យចិត្រាប្រឹងទប់ទូរសព្ទខ្លាចលាន់ចេញក្រៅ៖

«សើចឆ្កួតយកអីឯង?»

«អ្ហែងស្គាល់គេម៉ានបានកាន់ជើងបាត់ហើយអ្ហា? អាចៅចិត្រ!»

ចិត្រាគ្មានពេលកំដរខឹងដង នាយសួរវិញរឹង៖

«អាមានឯងរកឃើញថា អ្នករងគ្រោះបីទៀតមានស្លៀករ៉ូបវែងចូលរួមពិធីនៅថ្ងៃបាត់ខ្លួនដូចពិនណាកូនស្រីលោកមឿនពិនដែរអត់?»

ឯកមាន ឆ្លើយធ្វើងើយ៖

«ចង់ដឹងដល់ម្លឹងមិនសួររកឯកសារប៉ូលិសមើល? អញម៉េចនឹងដឹង?»

អារម្មណ៍ចិត្រាវិលខ្វាល់នឹកឃើញទៅដល់សំណុំឯកសារនៅឯកូនតុជាន់ខាងលើ។

«ស្តាយណាស់ គួរតែបើករបស់នោះមើល!»

គេរអ៊ូតិចៗ តែឯកមានឮច្បាស់។ បុរសអ្នកhackពោលសួរវិញបន្ទាន់៖

«បើកស្ទីគេឯង?»

«ស៊ូច! កុំមាត់! ឡើងទៅលើសិន កុំភ្លេចឮអ្វែស?»

ចិត្រាបែរខ្លួនចូលមកក្នុងផ្ទះ ស្របពេលត្រចៀកឮសំឡេងស្ត្រីចំណាស់ពោលប្រាប់អ្នកដែលបានជញ្ជូនរបស់មក៖

«អ្នកនាងប្រញាប់ចេញប្រលងភ្លេង អាវនេះទុកនៅនឹងខ្ញុំសិនចុះ!»

«ចាសមីង អ៊ីចឹងខ្ញុំសុំទៅសិនហើយ!»

«ចាស! ចាំអ្នកនាងទំនេរ គាត់ថានឹងទាក់ទងទៅ!»

«ចាសមីង!»

ស្ត្រីជូនដំណើរភ្ញៀវទៅក្រៅផ្ទះ ជាឱកាសដ៏តូចសម្រាប់នាយប៉ូលិស រត់ឡើងត្រឡប់ទៅជាន់ខាងលើវិញ។ គោលដៅសំខាន់ក្នុងពេលនេះគឺមើលឲ្យដឹងថាតើ ប៉ូលិសរកបានតម្រុយអ្វីខ្លះទាក់ទងនិងក្តីមនុស្សបាត់ខ្លួន?

«យើងគួរលួចអានវាឲ្យហើយមុននេះ!»

ចិត្រាគិតទាំងស្លុងជឿថា ប្រាកដជាមានសរសេរលម្អិត ពីការរកឃើញផ្សេងៗរបស់ប៉ូលិសនៅក្នុងសំណុំឯកសារដែលត្រូវបានលេចឡើង នៅឯជាន់ខាងលើនោះ។

អមរាដាកើតឆ្នាំរោង ហើយពេលនេះនាងស្រាប់តែកុម្ម៉ង់អាវរាត្រីសមោសរដែរ។ ហេតុអីមានរឿងជួនគ្នាទំនងម្ល៉េះ? ចុះប្រសិនបើឯកសារប៉ូលិសកត់ត្រាថា អ្នកបាត់ខ្លួនសុទ្ធតែបានតុបតែងខ្លួនមុនចាកចេញពីផ្ទះ ជាមួយសម្លៀកបំពាក់ចូលរួមពិធី?

ផាំង!!!

ស្នូរលាន់ឡើងច្បាស់ថៃសចេញពីបន្ទប់ខាងស្តាំដែលអង្គរក្សស្គាល់ថាជាបន្ទប់របស់នាង។

តាមសំឡេងអាចថា ជាអ្វីមួយជ្រុះ ឬសកម្មភាពមនុស្សប្រតាយប្រតប់គ្នា...

អង្គរក្សបាត់អស់អារម្មណ៍ចង់អានសំណុំរឿង តែបំបែរទិសដៅរត់រុញទម្លាយទ្វារចូលទៅរកនាង។ បន្ទប់ត្រូវរុញចូលមិនលំបាក បង្ហាញថាម្ចាស់បន្ទប់មិនបាននឹកស្មានដល់ថានឹងមានអ្នកណាមករុញចូលតក់ក្រហល់បែបនេះឡើយ។

ទោះយ៉ាងណា នៅក្នុងបរិវេណបន្ទប់គេងដ៏ប្រណីត គ្មានឃើញស្រមោលអ្នកណានៅទីនេះម្នាក់សោះ ហើយងាកទៅទ្វារកញ្ចក់ឯរានហាលខាងមុខ ក៏ចំហធ្លុង???

ស្រីៗទាំងពីរបាត់ទៅណាហើយ?

បេះដូងនាយសក្តិបួនលោតខុសចង្វាក់ ទោះធ្លាប់ឆ្លងកាត់ការលត់ដំក្រាស់ក្រែលកម្រិតណាក្តី។ អារម្មណ៍ចិត្រាពេលនេះ ស្រមៃឃើញតែម្យ៉ាងថា កូនស្រីទោលរបស់ឧត្តមសេនីយ៍ប្រាកដកំពុងតែក្លាយជាអ្នកបាត់ខ្លួនទី៥ប្រាកដណាស់ ហើយបាត់ទាំងកំពុងនៅក្នុងផ្ទះខ្លួនផ្ទាល់តែម្តង។ ចំណែករឿងផ្សេងទៀត គេលែងគិតឃើញទាំងអស់។

«បើកូនស្រីយើងមានអីកើតឡើង ឯងស្លាប់មិនខាន!»

សំឡេងប៉ារបស់នាងនៅតែលាន់រងំក្នុងចិត្ត ធ្វើឲ្យការត្រិះរិះរបស់ចិត្រារឹតតែវិលវល់ចាស់ដៃ។

នាយសក្តិបួនស្រែកហៅនាងឮៗ៖

«អ្នកនាងអមរាជាៗ?»

ជើងគេឈានយ៉ាងវែងឆ្ពោះតម្រង់ទៅរករានហាលខាងក្រៅ ព្រោះចំពោះមុខប៉ូលិសនេះគិតតែម្យ៉ាងថាគ្រប់អ្វីៗរួមទាំងសូរសំឡេងអម្បាញ់មិញ ពិតមានប្រភពមកពីខាងក្រៅនោះ។ ទោះយ៉ាងណា អ្វីមួយនៅលើពូកបានទប់ដំណើរនាយ ហើយសន្សឹមៗ លោកសក្តិបួនងាកមកយឺតៗ។

ប្រាកដណាស់! វាជាស្បោងក្រដាសទំនិញដែលមានរូប Logo ទំនងជាយីហោសម្លៀកបំពាក់គ្រឿង ក្នុងរបស់មនុស្សស្រី។

«ទីមួយស្រីៗបាត់ខ្លួនទាំងបួន សុទ្ធតែមានកំណាត់ហេតុកុម្ម៉ង់ខោអាវ ដេកយប់ដែលថ្លៃនិងសិចស៊ីបំផុត មុនពេលកើតហេតុមួយអាទិត្យ!» នេះជាអ្វីដែលប៉ូលិសកំពូលhack ទើបតែបានរំឭកប្រាប់នៅជាន់ខាងក្រោម។

ប៉ូលិសចិត្រារអ៊ូតិចៗ ទាំងផ្ទឹបទូរសព្ទក្បែរមាត់៖

«ខោអាវក្នុងនេះដឹង ដែលអាមានឆែកឃើញពួកអ្នកបាត់ខ្លួនមុនៗបានកុម្ម៉ង់ទិញ?»

«និយាយស្អីអ្នា?»

គេគ្មានចិត្តឯណានឹងឆ្លើយតបសំណួរទេ។

ដោយក្តីអន្ទះសាពុះពោរ បានជំរុញឲ្យបុរសអង្គរក្សដាច់ចិត្តលូកដៃទៅរាវខាងក្នុងស្បោងក្រដាស ហើយស្រវាចាប់លើកវត្ថុខាងក្នុងឡើង ដើម្បីនឹងពិនិត្យឲ្យអស់ក្តី។

បានដូចចិត្ត ដៃនាយជាប់មកជាមួយនូវអាវសរសៃសសូងរបស់មនុស្សស្រីពណ៌ស៊ីជម្ពូដែលធ្វើឲ្យកើតក្តីភិតភ័យ និងអៀនអន់ក្នុងពេលជាមួយគ្នា។

«ចប់ហើយ! គ្រឿងក្នុងមនុស្សស្រីដូចអាមានថាមែន! វីវរហើយ! យើងយឺតពេកហើយ! អត់បានការសោះអាអង្គរក្ស!»

គេគិតក្នុងចិត្តហើយសន្សឹមៗ ទីទើររវាងគួរទៅមុខ ឬបកមកទ្វារទៅរកលោកឧត្តមសេនីយ៍?

វិធីចុងក្រោយទំនងជាល្អជាង.....

ប៉ូលិសបែរមករកទ្វារខ្វាច់ របូតដៃជ្រុះអាវតូចកំប៉ិតពណ៌ស៊ីជម្ពូនោះធ្លាក់ដល់ដី ព្រោះស្រីស្អាតដូចទេពអប្សរម្ចាស់បន្ទប់កំពុងបង្ហាញខ្លួនទាំងបើកភ្នែកធំៗ។

រាងកាយនាងគ្របដោយកន្សែងពោះគោសមួយប៉ុណ្ណោះ បានន័យថានាងទើបនឹងចេញពីបន្ទប់ទឹក ព្រោះស្លន់ចំពោះកាលុកលុយស្រែករន្ទើនរបស់នាយ។

ផាច់!

ប៉ូលិសសក្តិបួនត្រូវមួយកំផ្លៀងជាលើកដំបូងក្នុងជីវិត...

«មនុស្សចិត្តធំ!!!»

នាងស្រែកគំហកអមជាមួយកំហឹងដៃ។

នៅពីក្រោយនាង លោកឧត្តមសេនីយ៍ លោកជំទាវនិងអ្នកម៉ាឡារត់ឡើងមកដល់ដោយតក់ស្លុត។

ក្រោយខ្នងនាយឯណោះវិញ ផានូបង្ហាញខ្លួនជាមួយនឹងកូនផើងបែកមួយសល់តែមួយផ្នែក។

«មានរឿងអី? ហើយ ហើយបងឯងហ៊ានម៉េះចូលក្នុងនេះ?»

ស្នូរអំបាញ់មិញដែលធ្វើឲ្យប៉ូលិសយើងយល់ច្រឡំគឺ នារីនេះធ្វើជ្រុះផើងផ្កាសោះ។

ក្ដីអាម៉ាស់កំពុងតែឡោមព័ទ្ធសក្ដិបួនកម្សត់។ នាយខំនិយាយមួយៗជ្រែកកាត់កែវភ្នែកតក់ស្លុតរបស់គ្រប់គ្រប់គ្នា៖

«ខ្ញុំស្មានថាអ្នកនាងមានគ្រោះថ្នាក់!»

មិនមាត់មួយម៉ាត់ ឧត្តមសេនីយ៍ធ្វើមុខមាំ ចំណែកស្រីតូចអមរាជាស្រែកតវ៉ាសំឡេងគ្រលួច ហើយចង្អុលទៅខោអាវក្នុងដែលជ្រុះលើឥដ្ឋ៖

«គ្រោះថ្នាក់ដល់ថ្នាក់មកស្រាវជ្រាវយករបស់របរអស់នេះចេញមកទៀត?»

នាងថាចប់ ចូលបន្ទប់ទឹកវិញបិទទ្វារគ្រាំង ទុកឲ្យលោកជំទាវវ៉ាស៊ីបញ្ជោឡើងទាំងកំហឹង៖

«លោកឯងចេញឲ្យបាត់ស្រមោលពីផ្ទះខ្ញុំ!»

ឧត្តមសេនីយ៍តាមសម្លឹងគេមិនដាក់ ទោះបីគេដើរកាត់លោកទាំងអាម៉ាស់។ ចិត្តមួយចង់និយាយបកស្រាយ ប៉ុន្តែមិនដឹងហាមាត់និយាយពីណាទៅណា ព្រោះពេលនេះការតូចក្លាយជាអាសន្នធំទៅហើយ។